ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១០០៩ ចុះថ្ងៃទី ០៩
ខែ ធ្នូ ឆ្នាំ ២០០៥
សាលក្រម
លេខ ៥១ ក ចុះថ្ងៃទី ១៣
ខែ មីនា ឆ្នាំ ២០០៦

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

ចៅក្រមជំនុំជំរះ

លោក [redacted] ជាប្រធានតុលាការខេត្តបាត់ដំបង

តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារងអមតុលាការខេត្តបាត់ដំបង

ក្រឡាបញ្ជីសវនាការ

លោក [redacted]

ដើម្បីជំនុំជំរះរឿងក្តីព្រហ្មទណ្ឌលេខ ១០០៩ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

១-ឈ្មោះ ឃ ឆទ ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ី ធ្វើស្រែចំការ មានទីកន្លែងកំណើតនៅភូមិថ្កូវ ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង មានកំរិតវប្បធម៌ថ្នាក់ទី៩ កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅភូមិថ្កូវ ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ ស ឃ (ស) មានម្តាយឈ្មោះ ស ឱ (រ) ទោសពីមុន *គ្មាន* ។

ត្រូវចាប់ខ្លួនកាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ នៅចំណុចភូមិប៉ុស្តិ៍កន្ទឺ ឃុំកន្ទឺ២ ស្រុកបាណន់ ខេត្តបាត់ដំបង និង ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅអាគារឃុំខ្លួននៃពន្ធនាគារខេត្តបាត់ដំបង តាមដីកាលេខ ៦០៣ ដឃខ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥ ។

២-ឈ្មោះ ស រស ហៅ ម ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីនៅរៀន មានទីកន្លែងកំណើតនៅភូមិថ្កូវ ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង មានកំរិតវប្បធម៌ថ្នាក់ទី៩ថ្មី កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅភូមិថ្កូវ ឃុំឈើទាល ស្រុកបាណន់ ខេត្តបាត់ដំបង នៅលីវ មានឪពុកឈ្មោះ ស ស (រ) មានម្តាយឈ្មោះ ស ៩ (រ) ទោសពីមុន *គ្មាន* ។ ត្រូវចាប់ខ្លួនកាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ នៅចំណុចផ្ទះរបស់ពលរដ្ឋឈ្មោះ ៣ ខ រស់នៅភូមិប៉ុស្តិ៍កន្ទឺ ឃុំកន្ទឺ២ ស្រុកបាណន់ ខេត្តបាត់ដំបង ។ ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ននៅអាគារឃុំខ្លួននៃពន្ធនាគារខេត្តបាត់ដំបង តាមដីកាលេខ ៦០២ ដឃខ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥ ហើយត្រូវបានអនុញ្ញាតអោយនៅក្រៅឃុំជាបណ្តោះអាសន្ន កាលពីថ្ងៃទី ២០ ខែ ធ្នូ

ឆ្នាំ ២០០៥ តាមដីកាសំរេចលេខ ១១៩ ដកក្រយ ។

ត្រូវចោទពីបទ **បង្ករបួសស្នាមដោយចេតនាឥតអាវុធ និង ជេរប្រមាថ ។**

តាមបញ្ញត្តិមាត្រា ៤១ និង មាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

ប្រព្រឹត្តនៅភូមិកន្ទី ឃុំកន្ទី២ ស្រុកបាណន់ ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ ។

មានលោក **ទ មរ** ការពារជនជាប់ចោទឈ្មោះ **ស រស** និង ឈ្មោះ **ហ ឆទ** ។

១-ជនរងគ្រោះឈ្មោះ **ឌ សរ** អាយុ ៣៦ឆ្នាំ ជាតិខ្មែរ របរកេស៊ីជានាយរងនគរបាលប៉ុស្តិ៍កន្ទី ២ មានទីលំនៅ ភូមិរាមគន់ ឃុំតារ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ ជាជនរងគ្រោះក្នុងរឿងបង្ករបួសស្នាម ។

២-នីតិបុគ្គលរងគ្រោះ គឺប៉ុស្តិ៍នគរបាលរដ្ឋបាលកន្ទី២ ដែលមានលោក **ជ ត** អាយុ ៤០ឆ្នាំ ជានាយប៉ុស្តិ៍នគរបាលរដ្ឋបាលកន្ទី២ ជាតំណាង ។ ដែលរងគ្រោះដោយអំពើជេរប្រមាថ ។

## ការប្រព្រឹត្តិទៅរបស់ជនជាប់ចោទ

កាលពីយប់ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ នៅភូមិកន្ទី ឃុំកន្ទី២ ស្រុកបាណន់ នៅផ្ទះរបស់ប្រជាពលរដ្ឋមួយមានប្រារព្ធពិធីឡើងគេហដ្ឋាន ពេលនោះក៏មានពិធីរាំលេងផងដែរ ។ ពេលកំពុងរាំលេងនោះមានរឿងឈ្លោះគ្នាមួយ ហើយនគរបាលនៅរក្សាសុវត្ថិភាពទីនោះចូលទៅឃាត់ ស្រាប់តែឈ្មោះ **ហ ឆទ** បានជេរនៅចំពោះមុខឈ្មោះ **ជ ត** ថា "អាពូកនគរបាលកន្ទី២" បន្ទាប់ពូកសមត្ថកិច្ចនាំខ្លួនឈ្មោះ **ហ ឆទ** ទៅអធិការដ្ឋាននគរបាលស្រុកបាណន់ ពេលនោះឈ្មោះ **ស រស** ទៅតាមមើលគ្នារបស់ខ្លួនឈ្មោះ **ហ ឆទ** ហើយបានជេរទៅអធិការនគរបាលស្រុកបាណន់ទៀត ។

តាមរបាយការណ៍លេខ ១២១/០៥ របតនប ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៥ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលកន្ទី២ បានបញ្ជាក់ថា នៅយប់ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ នៅផ្ទះរបស់ឈ្មោះ **ព ខ** អាយុ ៦៥ឆ្នាំ ភេទស្រី នៅភូមិកន្ទី មានដាក់ធុងបាស់រាំក្នុងពិធីឡើងផ្ទះ ហើយនគរបាលប៉ុស្តិ៍បានចាត់កំលាំងការពារសន្តិសុខចំនួន ០៥រូប ។ នេះដល់ម៉ោង ៩:១០នាទីយប់ មានក្មេងមួយក្រុមមិនស្គាល់បានជិះឡាន០១ ម៉ូតូ០១ ទៅឈប់ទិញស្រាផឹកអស់ប្រហែល ០២លីត្រផឹករួចឈ្លោះប្រកែកគ្នាជាមួយក្មេងមួយក្រុមទៀត ដែលរាំដូចគ្នាពេលនោះកំលាំងនគរបាលបានអន្តរាគមន៍ឃាត់ក្មេងនោះ នៅតែចចែសវាយគ្នាដដែល ក៏ឃាត់បានក្មេងម្នាក់ ឯក្រុមម្ខាងទៀតរត់ឡើងលើឡាន ហើយជេរប៉ូលីសថា អាចុយម្រាយប៉ូលីសកណ្តុយម៉ែវាចាប់ពូកអញ ហើយពូកនោះទៅករឿងឈ្មោះ **ស ទណ** ។

## នៅចំពោះមុខតុលាការពេលសវនាការ

-ជនជាប់ចោទឈ្មោះ **ហ ឆទ** បានឆ្លើយថា កាលពីយប់ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ ខ្លួន និង គ្នាខ្លួន ០២នាក់ទៀត គឺឈ្មោះ **ស រស** និង ឈ្មោះ **ទ ត** ជិះម៉ូតូរបស់ខ្លួនមួយគ្រឿងទៅមើលគេរាំបាស់នៅភូមិកន្ទី ស្រាប់តែពេលទៅដល់ខ្លួនបានរាំមួយបទ បន្ទាប់មានរឿងក្មេងៗឈ្លោះប្រកែកគ្នា ដែលពេលនោះខ្លួនឈរនៅក្រៅវង់ពុំបានឈ្លោះពុំបានជេរគេទេ ស្រាប់តែនគរបាលគេចាប់ខ្លួនបានតែម្តង ដោយមិនដឹងមានរឿងអ្វីផង ។

-ជនជាប់ចោទឈ្មោះ **ស រស** ហៅ **ម** បានឆ្លើយថា កាលពីយប់ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ ពូកខ្លួនមានគ្នា ០៣នាក់បានជិះម៉ូតូមួយគ្រឿងជារបស់ឈ្មោះ **ហ ឆទ** ទៅមើលគេរាំបាស់នៅភូមិកន្ទី ពេលរាំបានបន្តិចស្រាប់តែមានរឿងឈ្លោះគ្នា រវាងពូកគេដែលខ្លួនមិនស្គាល់ ហើយឃើញនគរបាលចាប់ឈ្មោះ **ហ ឆទ** ហើយនាំទៅអធិការដ្ឋានហើយខ្លួនក៏ទៅតាមស្រាប់តែនគរបាលឃាត់ខ្លួនទៀត ។

-ឈ្មោះ **ឱ សទ** ជាតំណាងនីតិបុគ្គលរងគ្រោះ គឺប៉ុស្តិ៍នគរបាលរដ្ឋបាលកន្ទី២បានបញ្ជាក់ថា កាលពីយប់ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ នៅផ្ទះប្រជាពលរដ្ឋមួយបានប្រារព្ធពិធីឡើងផ្ទះនៅភូមិកន្ទី ពេលនោះខ្លួនចាត់តាំងកំលាំង ០៥នាក់ ដើម្បីការពារសន្តិសុខ ឯខ្លួនទៅដែរ តែមិនបាននៅជាប់លាប់ទេ ដោយរវល់ស៊ីផឹកនៅផ្ទះគេមួយផ្សេងទៀត បន្ទាប់មានរឿងក្មេង១ឈ្លោះប្រកែកវាយគ្នា ខ្លួនបានចូលទៅឃាត់ ឯឈ្មោះ **ស រស**. **ហ ទ** និង គ្នាវាម្នាក់ទៀត អត់មានអ្នកណាជួយឃាត់ បានសំរុកទៅវាយពួកគេ ។ ខ្លួនបានឃាត់ឈ្មោះ **ហ ទ** ឯឈ្មោះ **ស សត** ឃាត់ខ្លួនឈ្មោះ **ស រស** តែខ្លួនមិនដឹងក្មេងនោះមានរឿងអ្វីទេ ។ ឈ្មោះ **ហ ឆទ** បានថាអោយខ្លួនថា បងឯងរាំនេះដឹងរឿងខ្ញុំទេ ហើយបានដាល់មុខខ្លួនបីដៃ តែមិនត្រូវដោយខ្លួនគេចទាន់ ។

-ឈ្មោះ **ជ ត** ជាសាក្សីបានឆ្លើយថា កាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ ពេលយប់ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ នៅភូមិកន្ទី មានពិធីរាំចុងបាស់ឡើងផ្ទះគេមួយ ពេលនោះមានរឿងក្មេងឈ្លោះគ្នា ហើយសមត្ថកិច្ចឃាត់បានជនសង្ស័យ ។

-សាក្សី **ម ជ** បានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ ពួកខ្លួនមានគ្នា ០៥នាក់ចាំការពារសន្តិសុខក្នុងពិធីឡើងផ្ទះគេមួយនៅភូមិកន្ទី ស្រាប់តែឮក្មេង១ឈ្លោះគ្នា ពេលនោះនៅចម្ងាយប្រហែល ១៥ម៉ែត្រពីរង់រាំ ស្រាប់តែឮមានការឈ្លោះគ្នា ហើយកំលាំងរបស់ខ្លួនចាប់បានតែជនល្មើសម្នាក់បញ្ជូនទៅអធិការដ្ឋាន ។ ពុំមានប៉ូលីសណាម្នាក់រងរបួសទេ ។

-តាមចម្លើយរបស់សាក្សីឈ្មោះ **ព ខ** បានញ្ជាក់ថា កាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ ពេលយប់នៅផ្ទះខ្លួនមានពិធីរាំលេងក្នុងពិធីឡើងផ្ទះ ពេលយប់នោះខ្លួនពុំដឹងខ្លួនថា មានការឈ្លោះប្រកែកអ្វីទេ ព្រោះខ្លួនសន្លប់ដោយរោគរបស់ខ្លួន ។

-តាមចម្លើយសាក្សីឈ្មោះ **ទ ត** បានបញ្ជាក់ថា កាលពីយប់ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ ពេលយប់ពួកខ្លួនមានគ្នា ០២នាក់ គឺឈ្មោះ **ទ រស** ឈ្មោះ **រេ** និង រូបខ្លួនបានទៅរាំក្នុងពិធីឡើងផ្ទះគេមួយក្នុងភូមិកន្ទី តែពេលទៅដល់ខ្លួនពុំបានចូលរាំដូចបីនាក់ទៀតទេ ពេលពួកគេរាំជិតបានមួយបទ ខ្លួនបានឮសម្លេងគេឈ្លោះគ្នា ហើយឃើញមនុស្សឈូរឆ បន្ទាប់មកខ្លួនឃើញប៉ូលីសចាប់បានឈ្មោះ **ហ ឆទ** ដោយមិនដឹងរឿងអ្វីទេ ។

-តាមចម្លើយសាក្សីឈ្មោះ **គ ហ** បានបញ្ជាក់ថា កាលពីយប់ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ ខ្លួនបានមកចាក់បាស់ក្នុងភូមិប៉ុស្តិ៍កន្ទី ឃុំកន្ទី២ ដោយចាក់បាស់តាំងពីម៉ោង ៦រហូតដល់ម៉ោង ៩:១០នាទីយប់ ស្រាប់តែឮសំឡេងស្រែកហោកញ្ជ្រៀវក្នុងរង់រាំ ពេលនោះមានក្មេង១ខ្លះកំពុងរាំលោត ខ្លះកំពុងបឹតស្រា ហើយបានវាយគ្នាក៏មានប៉ូលីសចូលទៅឃាត់ រួចបានឃើញក្មេងម្នាក់ហក់វាយប៉ូលីសម្នាក់ ដែលខ្លួនមិនស្គាល់ប៉ូលីសនោះទេ ។

## **<u>តំណាងអយ្យការសន្និដ្ឋានទោសថា</u>**

ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ ឈ្មោះ **ហ ឆទ**. **ស រស** និង បក្សពួកមិនស្គាល់ស្រវឹងស្រាទៅរាំក្នុងពិធីឡើងផ្ទះគេ ។ ឈ្មោះ **ហ ឆទ** បានបង្ករឿងជាមួយអ្នករាំ ប៉ូលីសចូលទៅឃាត់មិនស្តាប់ តែថែមទាំងវាយប៉ូលីសហើយត្រូវឃាត់ខ្លួន ។

ចោទឈ្មោះ **ហ ឆទ** ពីបទបង្ករបួស ឈ្មោះ **ស រស** មកជេរប៉ូលីស ។ ចោទឈ្មោះ **ហ ឆទ** តាមមាត្រា ២១ និង ចោទឈ្មោះ **ស រស** ពីបទជេរប្រមាថមានចែងក្នុងមាត្រា ៦៥ នៃច្បាប់អន្តរកាល ។

## **<u>មេធាវីការពារជនជាប់ចោទសន្និដ្ឋានការពារថា</u>**

ឆ្លងតាមការសួរដេញដោលពេលសវនាការ ចម្លើយជនជាប់ចោទ សាក្សី ។ តំណាងអយ្យការលើកឡើង ...សាក្សីមានលក្ខណៈខុសគ្នា ។ ព្រោះប៉ូលីសឈ្មោះ ជ ត ថា ពុំរបួសទេ តែអយ្យការចោទពីបទបង្ករបួសស្នាម ។ ...ជ សទ ឈរជាមួយឈ្មោះ ជ ត តែឈ្មោះ ជ ត ឆ្លើយថា មិនបាននៅកន្លែងកើតហេតុទេ ។ ជនរងគ្រោះថា ...តែពុំមែនគ្រេនទេ ។ ឈ្មោះ ឱ សទ ថា ពេលចាប់ឈ្មោះ ឆទ ឈ្មោះនេះគ្មានឈាមទេ តែដល់អធិការ ...ថា មើលមានហូរឈាម ។ ឈ្មោះ ឱ សទ ស្បៀកពាក់ស៊ីវិលក្របួចកឈ្មោះ ហ ឆទ ធ្វើអោយឈ្មោះ ហ ឆទ ...ធ្លាយ់ ។ ឈ្មោះ ស រស ថា ក្មេងឡើងឡានដែលជេរប៉ូលីស ។ រឿងហេតុនេះជនជាប់ចោទពុំជេរទេ ហើយ ...ការប្តឹងដែរ ។

## សំដីចុងក្រោយជនជាប់ចោទ

ជនជាប់ចោទឈ្មោះ ហ ឆទ បាននិយាយសំដីចុងក្រោយថា សុំតុលាការដោះលែងអោយខ្លួនមានសេរីភាព ...យុត្តិធម៌អោយខ្លួនផង ។

ជនជាប់ចោទឈ្មោះ ស រស បាននិយាយថា សំដីចុងក្រោយថា សុំលោកចៅក្រមលើកលែងទោសអោយ ...ផង ។

- -បានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទទាំង ០២នាក់
- -បានស្តាប់ចម្លើយអោយការណ៍របស់ជនរងគ្រោះ
- -បានស្តាប់ចម្លើយអោយការណ៍របស់សាក្សី
- -បានស្តាប់ការសួរដេញដោល ចោទឆ្លើយតទល់
- -បានពិនិត្យកំណត់ហេតុ ឯកសារ ភស្តុតាងនានា
- -បានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការ
- -បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ
- -បានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
- -បានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តបាត់ដំបង
## យល់ឃើញថា

-ពិតជាពុំកើតមាននូវអំពើបង្ករបួសស្នាម ដោយចេតនាឥតអាវុធនៅភូមិកទី ឃុំកទី២ ស្រុកបាណន់ ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ ដូចការចោទប្រកាន់ឡើយ ។

-ពិតជាកើតមាននូវអំពើជេរប្រមាថនៅភូមិកទី ឃុំកទី២ ស្រុកបាណន់ ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ ប្រាកដមែន ។

-អំពើជេរប្រមាថ ដែលកើតមាននៅទីកន្លែង និង ពេលវេលាដូចខាងលើពិតជាប្រព្រឹត្តឡើងដោយ ឈ្មោះ ហ ឆទ និង ឈ្មោះ ស រស បានជេរប្រមាថ ចំពោះកងកម្លាំងនគរបាលប៉ុស្តិ៍កទី២ និង អធិការ ស្រុកបាណន់ ។

-អំពើដែលជនជាប់ចោទទាំង ០២នាក់ បានប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចខាងលើនេះមានធាតុ ផ្សំគ្រប់គ្រាន់ជាជេរប្រមាថ ដូចមានបញ្ញត្តិក្នុងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ជនជាប់ចោទ

ទាំង ០២នាក់ជាសមត្ថជន ពួកគាត់មានអាយុ ១៧ឆ្នាំម្នាក់ ២០ឆ្នាំម្នាក់ ពួកគាត់មានស្មារតីជានាល្អ ពួកគាត់បានប្រព្រឹត្តអំពើដោយចេតនា ជេរប្រមាថចំពោះកងកម្លាំងនគរបាល ដែលបំពេញបេសកកម្មរក្សាសន្តិសុខ សណ្តាប់ធ្នាប់ក្នុងពិធីឡើងផ្ទះ ។

## យល់ឃើញថា

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ **ហ ឆទ** និង ឈ្មោះ **ស រស** ពីបទ ជេរប្រមាថ ប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចការចោទប្រកាន់របស់អយ្យការប្រាកដមែន ។

## ភស្តុតាងដាក់បន្ទុកមាន

-ចម្លើយរបស់ជនជាប់ចោទថា ខ្លួនមិនបានជេរចំពោះកងកម្លាំងនគរបាលគ្មានភស្តុតាងបញ្ជាក់ ។

-ចម្លើយអោយការណ៍របស់ជនរងគ្រោះ និង ចម្លើយអោយការរបស់សាក្សីបានឆ្លើយអោយការណ៍យ៉ាងច្បាស់ពីអំពើជេរប្រមាថរបស់ជនជាប់ចោទ ។

-កំណត់ហេតុ ឯកសារ ភស្តុតាងនានា ធ្វើឡើងដោយនគរបាលយុត្តិធម៌ ។

## ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី

១-អោយឈ្មោះ **ហ ឆទ** និង ឈ្មោះ **ស រស** រួចផុតពីការចោទប្រកាន **បង្ករបួសដោយចេតនាឥតអាវុធ** នៅភូមិកន្ទឹ ឃុំកន្ទឹ២ ស្រុកបាណន់ ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០០៥ ដែលត្រូវបានចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ១១៧ ដសសព ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៦ របស់អយ្យការអមតុលាការខេត្តបាត់ដំបង និង ដីកាបញ្ជូនរឿងអោយជំនុំជំរះលេខ ៤៦៤ ៣ស.ព្រទ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៦ របស់ចៅក្រមស៊ើបអង្កេត ។

តាមបទបញ្ញត្តិមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ។

២-ក-ផ្តន្ទាទោសឈ្មោះ **ហ ឆទ** ដាក់ពន្ធនាគារកំណត់ ០៣ខែ និង ០៤ថ្ងៃ គិតចាប់ពីថ្ងៃឃុំខ្លួន ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៥ ។

ខ-ផ្តន្ទាទោសឈ្មោះ **ស រស** ហៅ **ម** ដាក់ពន្ធនាគារកំណត់ ០២ខែគត់ តែទោសនេះអោយឈ្មោះ **ស រស** ទទួលទោសព្យួរ ដោយកំណត់រយៈពេលសាកល្បង ០៥ឆ្នាំ គិតចាប់ពីក្រោយពេលកាត់សេចក្តីនេះតទៅ ។

ពីបទ **ជេរប្រមាថ** ប្រព្រឹត្តនៅភូមិកន្ទឺ ឃុំកន្ទឺ២ ស្រុកបាណន់ ខេត្តបាត់ដំបង កាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥ ។

បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និង ការផ្តន្ទាទោស មានបញ្ញត្តិក្នុងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

តាមបញ្ញត្តិមាត្រា ៨ ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៣-សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ **ហ ឆទ** និង ឈ្មោះ **ស រស** ហៅ **ម** បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់រយៈពេល ០២ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជំរះ

[redacted]

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលក្រម អោយបានសំរេចតាមសាលក្រមនេះ និង អោយអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ ជួយអនុវត្ត បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

*បាត់ដំបង.ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៦*

ជ.ក្រឡាបញ្ជីសវនាការ

[redacted]

បានឃើញ

*បាត់ដំបង.ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៦*

ប្រធានតុលាការខេត្ត

[redacted]